រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

# សេចក្តីសំរេចលេខ ១៨ សសរ.

## ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-ឡាវ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្ម កិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសកិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ឡាវ ដែលមានសមាសភាព ដូចតទៅ :

១- ឯកឧត្តមទាំ គឹមហុន ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯកប៉ុល សារឿន អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ទីប្រឹក្សា

៣- ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- ឯកឧត្តម ម៉ុន សម អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម អភិបាលខេត្ត រតនគិរី សមាជិក

៦- ឯកឧត្តម អភិបាលខេត្ត ស្ទឹងត្រែង សមាជិក

៧- ឯកឧត្តម អភិបាលខេត្ត ព្រះវិហារ សមាជិក

៨- លោក ហួន សាខ៊ាង ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងនគរូនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍

៩- លោកឧត្តមសេនីយ៍ទោ ថៅ គន់ មេបញ្ជាការយោធភូមិភាគ១ សមាជិក

១០-លោកឧត្តមសេនីយ៍ត្រី ចាន់ អ៊ាន ប្រធាននាយកដ្ឋានព្រំដែនគោកក្រសួងមហាផ្ទៃ សមាជិក

១១-លោកឧត្តមនាវីទោ ឈុំ សុជាតិ ប្រធាននាយកដ្ឋានការពារព្រំដែននៃអគ្គសេនាធិការ សមាជិក

១២-លោក រស់ គន់ ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៣-លោក ឡុង ឌុល ប្រធានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៤-លោក អ៊ុក សុម៉ារីម ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ សមាជិក

១៥-លោកឧត្តមសេនីយ៍ត្រី ឆេត ចំរើន ប្រធាននាយកដ្ឋានភូមិសាស្ត្រក្រសួងការពារជាតិ សមាជិក

១៦-លោក ស៊ា គុសល អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

ប្រការ ២ : គណៈកម្មាធិការចំរុះ កិច្ចការព្រំដែនកម្ពុជា-ឡាវ មានភារកិច្ច ដូចខាងក្រោម :

ក- ពិនិត្យ និងដោះស្រាយរាល់បញ្ហាទាក់ទង និងការកំណត់ព្រំដែនកម្ពុជា-ឡាវ ។

ខ- ចរចាជាមួយភាគីឡាវ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាក់ទងនឹងការកំណត់ព្រំដែនកម្ពុជា-ឡាវ ។

គ- រៀបចំសន្ធិសញ្ញាសកំណត់ព្រំដែន ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ឃ- ដឹកនាំការងារ ខណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែន ។

ង- ដោះស្រាយនូវរាល់បញ្ហា ស្តីពីការអនុវត្តន៍លក្ខន្តិកៈព្រំដែនរវាងកម្ពុជា-ឡាវ ។

ច- ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសឡាវ ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់ការរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ ៖ ដើម្បីបំពេញការងារខាងលើនេះ គណៈកម្មាធិការចំរុះអាចនឹងបង្កើតក្រុមបច្ចេកទេសសំរាប់ធ្វើជាសេនាធិការ ។

ប្រការ ៤ ៖ គ្រប់សមាជិកនៃគណៈកម្មាធិការ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់គណៈកម្មាធិការ ។

ប្រការ ៥ ៖ គណៈកម្មាធិការនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ១៩ សសរ.

## ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-វៀតណាម

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន